និយាយនឹងមាត់ក៏ភ្លេចបាត់ដែរ ។ កាលពីមុន **សុជាខ្ញុំ** មានឈ្មោះថា **សាន សារី** ជូននឹងបងប្រុសខ្ញុំ **សាន សារុន** ប៉ុន្តែដោយឈឺច្រើនបែបនេះ ទើបប្រែក្លាយឈ្មោះថា **សាន សុខជា** ។ ក្រោយពេលបួសលោកគ្រូខ្ញុំបានកែថា **សាន សុជា** ដូច្នេះវិញ ។

## ផ្នែករបួសស្នាម

**សុជាខ្ញុំ** មានគ្រោះថ្នាក់ផ្នែកក្បាលបីដង មាត់និងធ្មេញម្តង ពោះម្តង ។ ផ្នែកក្បាលនោះគឺ :

លើកទី ១ កាលមិនទាន់ដឹងក្តី រត់ប្រណាំងជាមួយបងប្រុសទៅរកអ្នកម្តាយនៅឯចង្ក្រាន ដួលបោកនឹងជ្រុញ បែកត្រង់រង្វេលក្បាលចំពីខាងលើ, រឿងនេះខ្ញុំមិនចាំទេ ។

លើកទី ២ អាយុប្រហែល ៧ ឆ្នាំ នៅចាំបានថា រសៀលថ្ងៃមួយ ខ្ញុំបានហូបបាយកកនៅឯចង្ក្រាន ពាងលើផ្ទះអស់ទឹក ខ្ញុំក៏ចុះទៅផឹកទឹកក្នុងពាងខាងមុខផ្ទះ ។ គ្រាន់តែដាក់ជើងចុះស្រោប់តែរបូតដៃធ្លាក់ក្បាលទៅមុនបោកនឹងជ្រុញទ្រាប់ជើងទំហំប្រហែលពីរចំអាម ៤ ជ្រុង ត្រូវចំក្បាលខាងស្តាំ ដែលមើលឃើញស្នាមរហូតសព្វថ្ងៃនេះ ។ ដោយត្រូវខ្ទាំងពេក មិនឈឺទេ ទៅជាស្ពឹកអស់ ខ្ញុំខំក្រោកឈរឡើង

ស្រាប់តែមានអារម្មណ៍ថាមានទឹកក្ដៅ ៗ ហូរស្រោចលើខ្លួន តាមពិតទឹកនោះគឺជាឈាមដែលហូរចេញពីក្បាលខ្លួនឯង ។ ដោយខ្លាចលោកឪពុកបន្ទោស និងភាពល្ងង់ខ្លៅ ខ្ញុំក៏ប្រញាប់ជូតទឹកជួតជម្រះឈាមនោះចេញ តែទឹកនោះប្រែពណ៌ទៅជាក្រហមទាំងអស់ ។ មើលទៅឃើញថាឈាមរឹតតែច្រើន ឯកម្លាំងរឹតតែថយ **សុជា**ខ្ញុំក៏ខំវារឡើងតាមជណ្ដើរផ្ទះខាងមុខទៅរកលោកឪពុក ដែលអង្គុយវេញខ្សែនៅលើផ្ទះ លោកឪពុកគ្រាន់តែឃើញខ្ញុំប្រឡាក់ដោយឈាម តាំងពីក្បាលដល់ជើង នៅលើទីបំផុតនៃមាត់ជណ្ដើរ ក៏ស្ទុះមកចាប់ខ្ញុំដោយប្រញាប់ ។ ខ្ញុំមានការតក់ស្លុតជាខ្លាំង ដោយខ្លាចលោកឪពុកចាប់ខ្ញុំវាយ ព្រោះមិនចេះប្រយ័ត្ន ។ ការភ័យនេះ ខ្ញុំស្មើរតែរបូតដៃធ្លាក់ម្ដងទៀត ។ លោកឪពុកចាប់ខ្ញុំបញ្ជិះលើស្មារត់ទៅយ៉ាងលឿន សំដៅទៅផ្ទះជីដូន ។ កាលនោះមិនមានពេទ្យទេ លោកឪពុកនិងអ្នកភូមិបានយកកន្ត្រៃមកកាត់សក់ចេញ និងយកម្ជុលចេសសម្រាប់ដេរខោអាវមកដេរទាំងស្រស់តែម្ដង រួចទំពារស្លាចិញ្ចៀនបិទធ្វើជាថ្នាំ ឯចេសដែលដេរនោះ មិនបានហូតចេញទេ ប្រហែលជារលាយអស់ហើយ ។

លើកទី ៣ **សុជាខ្ញុំ**ធំបន្តិចហើយ រត់លេងបាល់ជាមួយក្មេងអ្នកស្រុក ក៏ជួលបោកនឹងថ្ម បែកចេញឈាមផ្នែកខាងក្រោយ តែមិនខ្លាំងដូចលើកទី ២ ទេ ហើយថ្នាំព្យាលបាល គឺស្មៅចិញ្ចៀនដដែល ។

ផ្នែកត្រង់មាត់និងធ្មេញ ដោយសារភាពរពឹសរបស់ក្មេង ខ្ញុំបានលោតចូលក្នុងធុងសាំងធំមួយ ដែលមានកម្ពស់ស្មើក្បាល ពេលលោត ដោយលំនឹងមិនល្អ ក៏បានបោកត្រូវចំមាត់ធុងនោះ មាត់ធុងរឹងជាងមាត់ខ្ញុំ បបូរមាត់ក៏បែក ធ្មេញខាងមុខរង្គើទាំងអស់ ឈាមហូរហោម អ្នកម្តាយបានឲ្យខ្ញុំបៀមស្រោដើម្បីឲ្យស្ពឹក ។ ធ្មេញដែលធ្លាប់តែល្អដូចធ្មេញកណ្តុរ ក៏ក្លាយជាធ្មេញដូចសព្វថ្ងៃនេះ ។ នេះកាលខ្ញុំនៅជាកុមារមុនបួស ។

ផ្នែកពោះ ធ្លាប់វះកាត់ខ្នែងពោះវៀនម្តង ។ ជាធម្មតា ការវះកាត់ខ្នែង គេចាត់ទុកថាជារឿងតូចតាចប៉ុណ្ណោះ តែចំពោះខ្ញុំប្រែក្លាយទៅជារឿងធំ គឺមុខរបួសមិនឆាយជា បេះតែមានខ្ទុះ ត្រូវរុះរើថ្នេរដេរឡើងវិញដល់ទៅពីរលើក សរុបទៅបីលើកទាំងពេលវះកាត់ផង ។ ពេលវះកាត់ **សុជាខ្ញុំ** ស្ថិតនៅក្នុងភេទជាភិក្ខុភាវៈ ។